UNITED NATIONS
INDUSTRIAL DEVELOPMENT ORGANIZATION

IN PARTNERSHIP WITH THE REPUBLIC OF KOREA

www.unido.org



©Dmitry Makeev

# CAMBODIA

## *គាំទ្ររាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តយុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍន៍ចម្បងប្រកបដោយប្រសិទ្ធភាព តាមរយៈការកសាងសមត្ថភាពស្ថាប័ន*

## បរិបទ

អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម (UNIDO) ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI) និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) បាន នឹងកំពុងសហការគ្នាអនុវត្តគម្រោង "គាំទ្ររាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តយុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍន៍ចម្បងប្រកបដោយប្រសិទ្ធភាព តាមរយៈការកសាងសមត្ថភាពស្ថាប័ន"។ គម្រោងដែលមានរយៈពេល៣៨ខែនេះ ធ្វើការជម្រុញដោះស្រាយនូវបញ្ហាអន្តរវិស័យរបស់កម្មវិធីភាពជាដៃគូប្រចាំប្រទេស (PCP) ។

វិស័យឧស្សាហកម្មកម្ពុជា រួមចំណែកជាង ៣០%នៃផលិតផលក្នុងស្រុកសរុប (GDP) ហើយត្រូវបានព្យាករណ៍ថានឹងបន្តមានកំណើនប្រកបដោយភាពរឹងមាំ។ វិស័យឧស្សាហ-កម្ម បាននឹងកំពុងពង្រីកបន្ថែម ដោយសារការនាំចេញផលិតផលពីឧស្សាហកម្មកាត់ដេរ សម្លៀកបំពាក់ និងស្បែកជើង ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ប្រទេសនេះនៅមានភាពទន់ខ្សោយនូវរចនាសម្ព័ន្ធឧស្សាហកម្ម មូលដ្ឋានតូចចង្អៀត ភាពទំនើបនៅមានកម្រិតទាប និងពឹងផ្អែកទាំងស្រុងទៅលើឧស្សាហកម្មកាត់ដេរ និងកែច្នៃអាហារ។ គោលបំណងមួយក្នុងចំណោមគោលបំណងសំខាន់ៗរបស់គម្រោងគឺ ដើម្បីគាំទ្ររាជរដ្ឋាភិបាលកម្ពុជាក្នុងការពង្រឹងសមត្ថភាពស្ថាប័នដើម្បីអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកាន់តែមានប្រសិទ្ធភាព និងធ្វើឲ្យប្រសើរឡើងនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម។

## អំពីគម្រោង

ពង្រឹងសមត្ថភាពស្ថាប័នទៅលើការតាក់តែង និងអនុវត្តគោលនយោបាយឧស្សាហកម្ម និងធ្វើឲ្យប្រសើរឡើងនូវគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ឧស្សាហកម្មសម្រាប់ប្រទេសកម្ពុជា

- ➢ លើកកម្ពស់ភាពប្រកួតប្រជែងផ្នែកឧស្សាហកម្ម
  - ពង្រឹងសមត្ថភាពរាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើសេចក្តីសម្រេចគោល-នយោបាយផ្អែកលើភស្តុតាង តាមរយៈការបណ្តុះបណ្តាលលើការវិភាគឧស្សាហកម្ម និងខ្សែចង្វាក់តម្លៃ
  - បង្ហាញពីការអនុវត្តល្អបំផុតក្នុងសកលលោក ដើម្បីដោះស្រាយបញ្ហាប្រឈម និងឧបសគ្គ តាមរយៈការសិក្សាស្រាវជ្រាវ សិក្ខាសាលា និងដំណើរទស្សន-កិច្ចសិក្សាលើប្រធានបទផ្សេងៗទាក់ទងនឹងវិស័យឧស្សាហកម្ម
- ➢ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម (IDP)
  - បង្កើតប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃថ្មីមួយ ដោយធ្វើការពិនិត្យមើលលើប្រព័ន្ធដែលកំពុងដំណើរការ ដើម្បីធ្វើការតាមដាន និងវាយតម្លៃគោលនយោបាយឧស្សាហកម្ម
  - ធ្វើការត្រួតពិនិត្យពាក់កណ្តាលអាណត្តិរបស់ IDP ជាមួយនឹងការត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយឧស្សាហកម្ម

## សង្ខេប

| |
|---|
| ឈ្មោះគម្រោង៖ គាំទ្ររាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តយុទ្ធសាស្ត្រ និងគោល-នយោបាយអភិវឌ្ឍន៍ចម្បងប្រកបដោយប្រសិទ្ធភាព តាមរយៈការកសាងសមត្ថភាពស្ថាប័ន |
| គោលបំណង៖ ដើម្បីគាំទ្ររដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកាន់តែមានប្រសិទ្ធភាព តាមរយៈការអភិវឌ្ឍសមត្ថភាពស្ថាប័ន |
| គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព៖ គោលដៅទី៩: ឧស្សាហកម្ម នវានុវត្តន៍ និងហេដ្ឋារចនាសម្ព័ន្ធ |
| ម្ចាស់ជំនួយ៖ សាធារណរដ្ឋកូរ៉េ (ROK) |
| ទីភ្នាក់ងារសមភាគី និងដៃគូអនុវត្ត៖ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI) ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (MEF) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) និងក្រសួងទេសចរណ៍ (MoT) |
| ថវិកា៖ ១.២០០.០០០ ដុល្លារអាមេរិក |
| រយៈពេល៖ ៣៨ខែ (ខែឧសភា ឆ្នាំ២០១៩ ដល់ខែមិថុនា ឆ្នាំ២០២២) |

*សំគាល់: គម្រោងត្រូវបានពន្យាពេលបន្ថែម៨ខែ (វិច្ឆិកា២០២១-មិថុនា២០២២)*

## ទំនាក់ទំនង

**លោក Isaksson Anders**
ប្រធានគម្រោង
A.Isaksson@unido.org

**លោក សុខ ណារិន**
តំណាងអង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្មប្រចាំប្រទេសកម្ពុជា
n.sok@unido.org

**លោកស្រី ឆាយ ពិដោរ**
អ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិ
p.chhay@unido.org